# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាបុណ្យរោយផេះ
## បឹងទំពុន ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩
## តើព្រះរបស់អ្នកនៅឯណា?

**អត្ថបទទី១៖ យ៉ូអែល ២,១២-១៨**

ចូរកែប្រែចិត្តគំនិត កុំហែកតែសម្លៀកបំពាក់ប៉ុណ្ណោះ! ចូរវិលមករកព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាវិញ ដ្បិតព្រះអង្គតែងតែប្រណីសន្ដោស ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរ ព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ ពោរពេញដោយព្រះហឫទ័យមេត្តាករុណា ព្រះអង្គមិនសព្វព្រះហឫទ័យដាក់ទោសទេ។ យអ ២,១៣

**អត្ថបទទី២៖ កូរិនថូស ទី២ ៥,២០-៦,២**

ព្រះគ្រីស្ដគ្មានបាបទាល់តែសោះ តែព្រះជាម្ចាស់បានធ្វើឲ្យព្រះអង្គទៅជាតួបាបសម្រាប់យើង ដើម្បីប្រោសយើងឲ្យបានសុចរិតរួមជាមួយព្រះគ្រីស្ដដែរ។ ២ករ ៥,២១

**ដំណឹងល្អ៖ ម៉ាថាយ ៦,១-៦.១៦-១៨**

រីឯអ្នកវិញ កាលណាដៃស្ដាំអ្នកធ្វើទាន មិនបាច់ឲ្យដៃឆ្វេងដឹងឡើយ។ មថ ៦,៣

បងប្អូនជាទីស្រឡាញ់!

យើងចូលនៅក្នុងរដូវ៤០ថ្ងៃហើយ ឆ្នាំនេះបុណ្យចម្លងមួយអាទិត្យក្រោយបុណ្យចូលឆ្នាំខ្មែរ ព្រះសហគមន៍ប្រទានពេលវេលាមួយយ៉ាងពិសេស ដើម្បីត្រៀមចិត្តគំនិត។ ថ្ងៃនេះយើងបានស្តាប់អត្ថបទទាំងបីដែលណែនាំឲ្យយើងដូចជាបានរកឃើញផ្លូវ ដើម្បីរៀបចំខ្លួននៅក្នុង៤០ថ្ងៃខាងមុខនេះ។ ក្នុងអត្ថបទទីពីរ "**យើងជាទូតរបស់ព្រះគ្រីស្ដ គឺដូចព្រះជាម្ចាស់មានព្រះបន្ទូលដាស់តឿនបងប្អូន**" នៅក្នុងអត្ថបទទីមួយ "**ចូរកែប្រែចិត្តគំនិត កុំហែកតែសម្លៀកបំពាក់ប៉ុណ្ណោះ សូមកុំបណ្ដោយឲ្យជាតិសាសន៍ទាំងឡាយពោលថា តើព្រះរបស់ពួកគេនៅឯណា?**" នៅក្នុងគម្ពីរដំណឹងល្អ "**កុំធ្វើបុណ្យទាននៅមុខមនុស្សម្នា ដើម្បីឲ្យគេឃើញនោះឡើយ កាលណាអ្នករាល់គ្នាធ្វើទានដល់អ្នកក្រីក្រ កាលណាអ្នករាល់គ្នាអធិដ្ឋាន កាលណាអ្នករាល់គ្នាតមអាហារ កុំធ្វើនៅមុខគេទាំងអស់ដើម្បីទទួលរង្វាន់នៅស្ថានបរមសុខនោះឡើយ**"។

យើងបានឃើញគម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់យើងរៀងៗខ្លួន យើងជាទូតរបស់ព្រះគ្រីស្ដ ឋានៈរបស់យើងជាបុត្រធីតារបស់ព្រះជាម្ចាស់។ នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ពិតមែនយើងទទួលជីវិតថ្មីដោយព្រះជាម្ចាស់លាងអំពើបាបរបស់យើងទាំងអស់ ប៉ុន្តែជាពិសេសគឺយើងចូលនៅក្នុងព្រះកាយព្រះគ្រីស្ដ និងទទួលព្រះសហគមន៍ដែលជាគ្រួសារថ្មីដោយសារយើងជាបុត្រធីតារបស់ព្រះជាម្ចាស់។ យើងទទួលបេសកកម្មមួយយ៉ាងពិសេសបំផុតគឺធ្វើជាទូតរបស់ព្រះអង្គ គឺលើផែនដីនេះយើងទទួលងារជាតំណាងរបស់ព្រះជាម្ចាស់យ៉ាង

ពិសេស ធ្វើយ៉ាងណាឲ្យមនុស្សឯទៀតៗអាចមើលឃើញព្រះជាម្ចាស់តាមរយៈយើង តាមរយៈរបៀបរបស់យើងរស់នៅ តាមរយៈសក្ខីភាពរបស់ព្រះសហគមន៍ តាមរយៈការរស់នៅតាមអំណោយទានដែលយើងបានទទួលជីវិតពីព្រះជាម្ចាស់យើងជាទូតរបស់ព្រះគ្រីស្ត។

ដើម្បីបំពេញបេសកកម្មរបស់យើង តួនាទីរបស់យើង ថ្ងៃនេះព្រះជាម្ចាស់មានព្រះបន្ទូលថា "**ចូរកែប្រែចិត្តគំនិត**" មិនមែនតែហែកសម្លៀកបំពាក់តែប៉ុណ្ណោះដើម្បីបង្ហាញឲ្យគេឃើញថា ខ្ញុំកំពុងរស់នៅតាមរបៀបថ្មីដោយកែប្រែចិត្តគំនិត។ ប៉ុន្តែថ្ងៃនេះព្រះសហគមន៍អញ្ជើញយើង ឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង នៅក្នុងជីវិតរបស់យើងផ្ទាល់ ដើម្បីមើលឃើញនៅក្នុងដួងចិត្តរបស់យើងមានអ្វីខ្លះ? "**សូមកុំបណ្តោយឲ្យជាតិសាសនទាំងឡាយពោលថា តើព្រះរបស់ពួកគេនៅឯណា?**" កុំឲ្យបងប្អូនឯទៀតៗដែលមិនស្គាល់ព្រះជាម្ចាស់សួរដល់យើង នៅពេលគេឃើញរបៀបដែលយើងរស់នៅ របៀបដែលយើងបង្កើតទំនាក់ទំនងជាប្រចាំថ្ងៃ សួរដល់យើងតើព្រះរបស់អ្នកនៅឯណា? ព្រះបន្ទូលមួយថា "**នៅពេលយើងស្រឡាញ់គ្នាទៅវិញទៅមក នៅពេលហ្នឹងយើងបង្ហាញអំពីវត្តមានរបស់ព្រះជាម្ចាស់ នៅពេលយើងចេះរួមរស់ជាមួយគ្នាដូចបងប្អូនបង្កើតនៅពេលហ្នឹងយើងបង្ហាញវត្តមានរបស់ព្រះជាម្ចាស់ពិតមែន**"។ យើងរស់នៅក្នុងសង្គមគោរពព្រះពុទ្ធសាសនា យើងជាគ្រីស្តបរិស័ទតិច តែយើងត្រូវតែផ្តល់សក្ខីភាពដើម្បីបង្ហាញដល់បងប្អូនឯទៀតៗព្រះជាម្ចាស់របស់យើងនៅឯណា? ប៉ុន្តែរបៀបដែលយើងត្រូវការបង្ហាញមិនមែនតាមរបៀបលោកីយ៍ ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលយ៉ាងច្បាស់ថា "**នៅពេលយើងធ្វើបុណ្យទានកុំឲ្យយើងធ្វើនៅមុខគេកុំឲ្យគេឃើញ**" បើយើងធ្វើឲ្យគេឃើញយើងមិនបានទទួលរង្វាន់ពីព្រះជាម្ចាស់សោះ។ ដូច្នេះដើម្បីបង្ហាញវត្តមានរបស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ គឺរបៀបដែលយើងត្រូវតមអាហារ របៀបដែលយើងត្រូវអធិដ្ឋាន របៀបដែលយើងត្រូវជួយបងប្អូនឯទៀតៗ។ សម្តេចប៉ាប បានរំលឹកយើងថា ព្រះជាម្ចាស់បានបង្កើតពិភពលោកទាំងមូល ដែលមានកំពូលនៃពិភពលោកគឺមនុស្សយើងដែលមានលក្ខណៈរបស់ព្រះជាម្ចាស់ ដែលជាតំណាងរបស់ព្រះអង្គ។ មានន័យថាមនុស្សយើងដែលជាបុត្រធីតារបស់ព្រះជាម្ចាស់ ពោរពេញដោយសេចក្តីស្រឡាញ់ដែលយើងបានទទួលនៅថ្ងៃយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ពីព្រះជាម្ចាស់ផ្ទាល់។ មនុស្សយើងត្រូវការធ្វើយ៉ាងណា ដើម្បីបង្ហាញអំពីវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោកទាំងមូលដែលសុទ្ធតែជាស្នាព្រះហស្តរបស់ព្រះអង្គ ទាំងដើមឈើ ទាំងធម្មជាតិ នឹងយើងទាំងអស់គ្នាយើងធ្វើយ៉ាងមិចដើម្បីការពារថែរក្សាស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅក្នុងជិវិតរបស់យើង។

សម្តេចប៉ាបបានរំលឹកយើងថា នៅពេលយើង**តមអាហារ** មិនមែនតែកាត់បន្ថយម្ហូបអាហារ ប៉ុន្តែសំខាន់បំផុតឲ្យយើងដូររបៀបដែលយើងបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗពីមួយថ្ងៃទៅមួយថ្ងៃ។ ដូររបៀបដែលយើងបង្កើតទំនាក់ទំនងជាមួយធម្មជាតិដែលព្រះជាម្ចាស់

បានបង្កើត កុំឲ្យយើងទៅជាមនុស្សដែលចង់បានអ្វីៗទាំងអស់សម្រាប់យើងផ្ទាល់ខ្លួន កុំឲ្យយើងទៅជាមនុស្សដែលចង់រស់នៅ ដែលគិតតែអំពីផ្ទាល់ខ្លួនឥតចេះមើលដល់អ្នកដទៃ។ ផ្ទុយទៅវិញឲ្យយើងយកចិត្តទុកដាក់មានឫសនៃសេចក្តីស្រឡាញ់ក្នុងខ្លួនយើង ដើម្បីលះបង់ចោលភាពអត្តានិយមដែលយើងមាននៅក្នុងដួងចិត្តរបស់យើង ឲ្យមានកន្លែងសម្រាប់បងប្អូនឯទៀតៗនៅក្នុងដួងចិត្តរបស់យើងនិងជាពិសេសដល់ព្រះជាម្ចាស់។ ហេតុនេះហើយ ឆ្នាំនេះឲ្យយើងបង្កើតទំនាក់ទំនងថ្មីជាមួយបងប្អូនឯទៀតៗ ជាមួយធម្មជាតិដែលមានជុំវិញយើង ដើម្បីបង្ហាញតាមរបៀបដែលយើងរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីបង្ហាញនេះជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ ជីវិតខ្ញុំជាជីវិតដែលខ្ញុំបានទទួលពីព្រះជាម្ចាស់ ប៉ុន្តែជីវិតរបស់បងប្អូនឯទៀតៗដែលមិនមែនជាព្រះគ្រីស្តបរិស័ទក៏ជាជីវិតពិសេសដែលពួកគាត់បានទទួលពីព្រះជាម្ចាស់ដែរ។ យើងធ្វើយ៉ាងណា ដើម្បីការពារថែរក្សាតម្លៃថ្លៃថ្នូរនៃជីវិត ជីវិតទាំងអស់ដែលយើងបានទទួលពីព្រះជាម្ចាស់ផ្ទាល់។

**អធិដ្ឋាន** ដោយដឹងថាជីវិតរបស់យើងមិនអាចទីពឹងលើខ្លួនឯងតែប៉ុណ្ណឹង យើងត្រូវទីពឹងលើព្រះជាម្ចាស់ដែលបានបង្កើតយើង។ នៅពេលជីវិតរបស់យើងទីពឹងលើព្រះជាម្ចាស់ យើងនឹកឃើញដល់ស្ថានភាពរបស់យើង ដល់អំពើបាបរបស់យើង ឲ្យយើងយល់ថាដើម្បីរស់នៅយ៉ាងសមរម្យនឹងឋានៈរបស់យើងដែលជាបុត្រធីតារបស់ព្រះជាម្ចាស់។ យើងទីពឹងលើព្រះជាម្ចាស់ដើម្បីទទួលព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ក្នុងរដូវ៤០ថ្ងៃជាពេលវេលាដែលយើងត្រូវកែប្រែចិត្តគំនិត ដើម្បីទទួលអគ្គសញ្ញាលើកលែងទោសដែលមកពីព្រះជាម្ចាស់ផ្ទាល់ ដោយទទួលស្គាល់ថា ពិតមែនយើងជាមនុស្សដែលពោរពេញដោយអំពើបាប ប៉ុន្តែព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ លុះត្រាតែខ្ញុំសុខចិត្តកែប្រែចិត្តគំនិតដើម្បីរស់នៅតាមរបៀបថ្មី និងដើម្បីបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ ឲ្យគេឃើញថាដើម្បីរស់នៅដ៏ពេញលក្ខណៈយើងត្រូវតែទីពឹងលើព្រះជាម្ចាស់ដោយអធិដ្ឋានជាប្រចាំ។ ដូច្នេះនោះក្នុងរដូវ៤០ថ្ងៃនេះ ឲ្យយើងយកចិត្តទុកដាក់ទាំងតមអាហារ ទាំងអធិដ្ឋាន ស្តាប់ព្រះបន្ទូលដើម្បីដឹងថាពិតមែនខ្ញុំទីពឹងលើព្រះជាម្ចាស់។

ឲ្យយើងយកចិត្តទុកដាក់**ចែករំលែក**ជាមួយបងប្អូនឯទៀតៗ សង្គមបច្ចុប្បន្នចង់ឲ្យយើងមានច្រើនទៅៗ ឲ្យយើងទទួលអ្វីៗទាំងអស់សម្រាប់ជីវិតរបស់យើង។ ប៉ុន្តែមានបងប្អូនយ៉ាងច្រើនកំពុងខ្វះខាត ដូច្នេះយើងធ្វើយ៉ាងមិច ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតមួយដែលចេះចែករំលែកទាំងសេចក្តីស្រឡាញ់ ទាំងពេលវេលា ទាំងអំណោយទាននៃជីវិតដែលយើងបានទទួលទាំងទ្រព្យសម្បត្តិរបស់យើងផ្ទាល់ខ្លួនដល់បងប្អូនឯទៀតៗ។

ថ្ងៃនេះជាថ្ងៃទីមួយនៃរដូវ៤០ថ្ងៃ យើងមានតែប្រាំអាទិត្យកុំឲ្យយើងចាំយូរពេក ឲ្យយើងចាប់ផ្តើមនឹកឃើញ **តើខ្ញុំធ្វើយ៉ាងណាដើម្បីឲ្យឆ្នាំនេះ យើងតមអាហារថែមទៀតដោយបង្កើតទំនាក់ទំនងថ្មីជាមួយបងប្អូនឯទៀតៗ និងជាមួយធម្មជាតិ? តើខ្ញុំធ្វើយ៉ាងណាដើម្បីឲ្យឆ្នាំនេះ អធិ**

**ដ្ឋានថែមទៀត? តើឆ្នាំនេះ ខ្ញុំសម្រេចចិត្តធ្វើអ្វីខ្លះដល់បងប្អូនឯទៀតៗ ដល់មនុស្សម្នាក់ដែលយើងឃើញពីមួយថ្ងៃទៅមួយថ្ងៃគេអស់សង្ឃឹមនៅក្នុងជីវិត?** ខ្ញុំធ្វើយ៉ាងណាដើម្បីបង្កើតទំនាក់ទំនងមួយយ៉ាងពិសេស ដើម្បីចែករំលែកអំណោយទាននៃជីវិតនិងសេចក្តីស្រឡាញ់ ដែលយើងបានទទួលពីព្រះជាម្ចាស់។

ដូច្នេះថ្ងៃនេះ ឲ្យយើងសម្រេចចិត្តយ៉ាងជាក់ស្តែងឆ្នាំនេះខ្ញុំកែប្រែចិត្តគំនិត ដើម្បីធ្វើជាទូតរបស់ព្រះគ្រីស្តដ៏ពិតប្រាកដមែន និងជាពិសេសដើម្បីបង្ហាញវត្តមានរបស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗដែលកំពុងសួរដល់ខ្ញុំ **តើព្រះរបស់អ្នកនៅឯណា?** អាម៉ែន៕